01426062

**Declassified to Public**
**28 June 2019**

លេខ៖ D350

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 29 / 03 / 2017
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧

ភាសា ៖ អង់គ្លេស និងខ្មែរ [អង់គ្លេស ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

# ដីកាសម្រេចកែប្រែបទចោទប្រកាន់ យឹម ទិត្យ

**<u>ផ្ញើជូន៖</u>**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្ដី យឹម ទិត្យ**

សូ មូស្សេនី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARTI

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ និងថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧។

២. នៅថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧ នៅក្នុងសេចក្តីជូនដំណឹងអំពីចេតនាបន្ថែមទម្រង់នៃការទទួលខុសត្រូវ តាមវិធីដីកាបង្គាប់របស់តុលាការ និងការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន ("សេចក្តីជូនដំណឹង")[1] ខ្ញុំបានជូនដំណឹងភាគីទាំងអស់អំពីចេតនារបស់ខ្ញុំបន្ថែមទម្រង់នៃការទទួលខុសត្រូវទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មដែលបានដាក់ឲ្យស្ថិតក្រោមការពិនិត្យនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥[2] តាមវិធីចេញដីកាជាលាយលក្ខណ៍អក្សរកែប្រែបទចោទ។

៣. នៅក្នុងសេចក្តីជូនដំណឹង ខ្ញុំបានអញ្ជើញភាគីទាំងអស់ឲ្យដាក់សារណាអំពីបញ្ហានេះ[3]។

៤. នៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ចម្លើយតប[4] ដោយបញ្ជាក់ថា គាត់មិនជំទាស់នឹងការប្រើប្រាស់ដីកាបង្គាប់របស់តុលាការដើម្បីកែប្រែបទចោទប្រឆាំងយឹម ទិត្យ ទេ[5]។

៥. យឹម ទិត្យ មិនបានដាក់សារណាលើបញ្ហានេះទេ។

---

[1]សំណុំរឿង ០០៤ ឯកសារ D342 *សេចក្តីជូនដំណឹងអំពីចេតនាបន្ថែមទម្រង់នៃការទទួលខុសត្រូវ តាមវិធីដីកាបង្គាប់របស់តុលាការ និងការផ្អាកកិច្ចស៊ើបសួរបណ្តោះអាសន្ន* ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧("សេចក្តីជូនដំណឹង")។

[2]សំណុំរឿង ០០៤ ឯកសារ D281 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥("ការបង្ហាញខ្លួនលើកដំបូង")។

[3]សេចក្តីជូនដំណឹង កថាខណ្ឌ ៤៥,៤៨។

[4]សំណុំរឿង ០០៤ ឯកសារ D342/1 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីចេតនាដាក់បន្ថែមទម្រង់នៃការទទួលខុសត្រូវ តាមវិធីដីកាបង្គាប់របស់តុលាការ និងអំពីការផ្អាកជាបណ្តោះអាសន្ន* ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១៧ ("ចម្លើយតប")។

[5] ចម្លើយតប កថាខណ្ឌ ២។

**អាស្រ័យហេតុនេះ ខ្ញុំ៖**

៦. **ជូនដំណឹង** យឹម ទិត្យ អំពីបទចោទដែលបានកែប្រែដូចបានបង្ហាញនៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងដីកាសម្រេចនេះ ហើយឥឡូវនេះ ឧបសម្ព័ន្ធនេះបង្ហាញពីបទចោទគាត់ទាំងអស់។

ភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**